ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសាធារណការ និងដឹកជញ្ជូន
លេខ: ៤៦៤ ប្រក.សក.ដជគ

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

# ប្រកាសអន្តរក្រសួង
# ស្តីពី
# បែបបទ និងនីតិវិធីនៃការផ្ទេរកម្មសិទ្ធិយានជំនិះ

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកត/០៣២០/២៤១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១២/០១០ ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់គ្រប់គ្រងឆ្នាំ ២០១៣

- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១៥/០០១ ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៥/០១៦ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់គ្រប់គ្រងឆ្នាំ ២០១៦
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១៧/០០២ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា៨ មាត្រា៤០ មាត្រា៤១ មាត្រា៤៧ មាត្រា៤៨ មាត្រា៧៥ មាត្រា៧៧ មាត្រា៨២ និងមាត្រា៩០ នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ដែលត្រូវប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០១១៥/០០១ ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ២០១៥
- បានឃើញអនុក្រឹត្យលេខ ០៨/អនក្រ ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ១៩៩១ ស្តីពីការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទ
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៩៩១ ស្តីពីការប្រមូលពន្ធប្រថាប់ត្រា
- បានឃើញអនុក្រឹត្យលេខ ៧៧ អនក្រ.បក ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០០៣ ស្តីពីការចេញផ្លាកលេខសម្គាល់យានជំនិះ
- បានឃើញអនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន និងអនុក្រឹត្យលេខ ២២០ អនក្រ.បក ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីការដំឡើងនាយកដ្ឋានសំណង់ប្រព័ន្ធចម្រោះទឹកកខ្វក់ ទៅជាអគ្គនាយកដ្ឋានប្រព័ន្ធចម្រោះទឹកកខ្វក់ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ៥០៧ សហវ.ប្រក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៧ ស្តីការប្រមូលពន្ធប្រថាប់ត្រា
- បានឃើញប្រកាសលេខ ៥៣១ សហវ.ប្រក ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៨ ស្តីពីការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទប្រចាំឆ្នាំ
- បានឃើញអនុក្រឹត្យលេខ ៧៣ អនក្រ.បក ចុះថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១៩ ស្តីពីការចុះបញ្ជីផ្តល់បណ្ណសម្គាល់យានជំនិះ និងបំពាក់ផ្លាកលេខសម្គាល់យានជំនិះ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសាធារណការ និងដឹកជញ្ជូន និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ១.-**

ប្រកាសនេះមានគោលបំណងគ្រប់គ្រងយានជំនិះដើម្បីធានាសន្តិសុខ សណ្តាប់ធ្នាប់ សុវត្ថិភាព និងកម្មសិទ្ធិស្របច្បាប់លើយានជំនិះ។

**ប្រការ២.-**

ប្រកាសនេះ មានគោលដៅកំណត់បែបបទ និងនីតិវិធីនៃការផ្ទេរកម្មសិទ្ធិយានជំនិះគ្រប់ប្រភេទនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ៣.-**

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះការផ្ទេរកម្មសិទ្ធិយានជំនិះគ្រប់ប្រភេទ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ៤.-**

ការផ្ទេរកម្មសិទ្ធិយានជំនិះគ្រប់ប្រភេទ តម្រូវឱ្យដាក់ពាក្យសុំផ្ទេរកម្មសិទ្ធិយានជំនិះ នៅទីតាំងផ្តល់សេវាសាធារណៈដែលកំណត់ដោយក្រសួងសាធារណការ និងដឹកជញ្ជូន ឬតាមរយៈប្រព័ន្ធស្វ័យប្រវត្តិកម្មចុះបញ្ជីយានជំនិះដែលមានអាសយដ្ឋានគេហទំព័រ https://vehicle.mpwt.gov.kh តាមគំនូសបំព្រួញអំពីដំណើរការនៃការផ្ទេរកម្មសិទ្ធិយានជំនិះ ដូចមានចែងក្នុងឧបសម្ព័ន្ធទី៥ នៃប្រកាសអន្តរក្រសួងនេះ។

ម្ចាស់កម្មសិទ្ធិយានជំនិះអាចមានជម្រើសក្នុងការបង់ពន្ធប្រថាប់ត្រាលើការផ្ទេរកម្មសិទ្ធិយានជំនិះ ដោយដាក់ពាក្យស្នើសុំនៅតាមសាខាពន្ធដារខេត្ត-ខណ្ឌនៅទូទាំងប្រទេស ឬតាមរយៈប្រព័ន្ធស្វ័យប្រវត្តិកម្មរបស់អគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលមានអាសយដ្ឋានគេហទំព័រ https://www.tax.gov.kh។

ម្ចាស់កម្មសិទ្ធិយានជំនិះ និង ម្ចាស់គ្រប់គ្រងជាក្រសួង ស្ថាប័ន ស្ថានទូត អង្គការសហប្រជាជាតិ អង្គការជាតិ អន្តរជាតិ ម្ចាស់គ្រប់គ្រងយានជំនិះក្រោមរបបគយនាំចូលបណ្តោះអាសន្ន ត្រូវដាក់ពាក្យស្នើសុំផ្ទេរកម្មសិទ្ធិយានជំនិះ ទៅទីតាំងផ្តល់សេវាសាធារណៈនៅអគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវគោក។

**ប្រការ៥.-**

ការផ្ទេរកម្មសិទ្ធិយានជំនិះគ្រប់ប្រភេទ ត្រូវភ្ជាប់មកជាមួយនូវសំណុំឯកសារទៅតាមករណីនីមួយៗ ដូចខាងក្រោម៖

**១. ការផ្ទេរកម្មសិទ្ធិយានជំនិះពីរូបវន្តបុគ្គល ទៅរូបវន្តបុគ្គល ៖**

- ពាក្យសុំផ្ទេរកម្មសិទ្ធិយានជំនិះ
- បណ្ណសម្គាល់យានជំនិះ (ច្បាប់ដើម) និងផ្លាកលេខសម្គាល់យានជំនិះ (ករណីផ្ទេរកម្មសិទ្ធិឆ្លងរាជធានី ខេត្ត)
- វិញ្ញាបនបត្រត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានជំនិះ
- អត្តសញ្ញាណអ្នកលក់ និងអ្នកទិញ៖
    - ពលរដ្ឋខ្មែរ៖ អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ច្បាប់ចម្លងដែលមានបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច
    - ជនបរទេស៖ លិខិតឆ្លងដែន និងទិដ្ឋាការមានសុពលភាព និងលិខិតបញ្ជាក់ទីលំនៅបច្ចុប្បន្នចេញដោយអាជ្ញាធរមានសមត្ថកិច្ច
- បង្កាន់ដៃពន្ធប្រថាប់ត្រាលើការផ្ទេរកម្មសិទ្ធិយានជំនិះ (ជាទម្រង់ឌីជីថល)

- លិខិតលក់ទិញ ត្រូវធ្វើឡើងនៅទីតាំងផ្តល់សេវាសាធារណៈ និងចំពោះមុខមន្ត្រីមានសមត្ថកិច្ចផ្ទេរកម្មសិទ្ធិយានជំនិះ។

## ២. ការផ្ទេរកម្មសិទ្ធិយានជំនិះរវាងនីតិបុគ្គលឯកជន និងរូបវន្តបុគ្គល

- ពាក្យសុំផ្ទេរកម្មសិទ្ធិយានជំនិះ
- បណ្ណសម្គាល់យានជំនិះ (ច្បាប់ដើម) និងផ្លាកលេខសម្គាល់យានជំនិះ (ករណីផ្ទេរកម្មសិទ្ធិឆ្លងរាជធានី ខេត្ត)
- វិញ្ញាបនបត្រត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានជំនិះ
- អត្តសញ្ញាណអ្នកលក់ និងអ្នកទិញ៖
  - ពលរដ្ឋខ្មែរ៖ អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ច្បាប់ចម្លងដែលមានបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច
  - ជនបរទេស៖ លិខិតឆ្លងដែន និងទិដ្ឋាការមានសុពលភាព និងលិខិតបញ្ជាក់ទីលំនៅបច្ចុប្បន្នចេញដោយអាជ្ញាធរមានសមត្ថកិច្ច
  - ក្រុមហ៊ុន៖ វិញ្ញាបនបត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងបណ្ណពន្ធប៉ាតង់ច្បាប់ចម្លងដែលមានបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច
- បង្កាន់ដៃពន្ធប្រថាប់ត្រាលើការផ្ទេរកម្មសិទ្ធិយានយន្ត (ជាទម្រង់ឌីជីថល)
- លិខិតលក់ទិញដែលមានចុះហត្ថលេខា និងបោះត្រាក្រុមហ៊ុន និង/ឬវិក្កយបត្រអាករ។

## ៣. ការផ្ទេរកម្មសិទ្ធិយានជំនិះពីនីតិបុគ្គលសាធារណៈ (កម្មសិទ្ធិក្រសួង ស្ថាប័នរដ្ឋ) ទៅរូបវន្តបុគ្គល ឬនីតិបុគ្គលឯកជន

- ពាក្យសុំផ្ទេរកម្មសិទ្ធិយានជំនិះ
- បណ្ណសម្គាល់យានជំនិះ (ច្បាប់ដើម) និងផ្លាកលេខសម្គាល់យានជំនិះ
- អត្តសញ្ញាណអ្នកទិញ
  - ពលរដ្ឋខ្មែរ៖ អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ច្បាប់ចម្លងដែលមានបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច
  - ជនបរទេស៖ លិខិតឆ្លងដែន និងទិដ្ឋាការមានសុពលភាព និងលិខិតបញ្ជាក់ទីលំនៅបច្ចុប្បន្នចេញដោយអាជ្ញាធរមានសមត្ថកិច្ច
  - ក្រុមហ៊ុន៖ វិញ្ញាបនបត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងបណ្ណពន្ធប៉ាតង់ច្បាប់ចម្លងដែលមានបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច
- វិញ្ញាបនបត្រត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានជំនិះ
- បំពេញកាតព្វកិច្ចពន្ធ និងអាករ (ករណីយានជំនិះមានបង្កាន់ដៃពន្ធយានយន្តជាបន្ទុករបស់រដ្ឋ)
- បង្កាន់ដៃពន្ធប្រថាប់ត្រាលើការផ្ទេរកម្មសិទ្ធិយានជំនិះ (ជាទម្រង់ឌីជីថល) ក្នុងករណីយានជំនិះមានបង្កាន់ដៃពន្ធយានយន្តមិនមែនជាបន្ទុករបស់រដ្ឋ
- លិខិតជម្រះបញ្ជីចេញដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

## ៤. ការផ្ទេរកម្មសិទ្ធិយានជំនិះពីកម្មសិទ្ធិស្ថានទូត អង្គការសហប្រជាជាតិ អង្គការអន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាល ទៅរូបវន្តបុគ្គល ឬនីតិបុគ្គលឯកជន

- ពាក្យសុំផ្ទេរកម្មសិទ្ធិយានជំនិះ

- បណ្ណសម្គាល់យានជំនិះ (ច្បាប់ដើម) និងផ្លាកលេខសម្គាល់យានជំនិះ
- អត្តសញ្ញាណអ្នកទិញ
  - ពលរដ្ឋខ្មែរ៖ អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ច្បាប់ចម្លងដែលមានបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច
  - ជនបរទេស៖ លិខិតឆ្លងដែន និងទិដ្ឋាការមានសុពលភាព និងលិខិតបញ្ជាក់ទីលំនៅបច្ចុប្បន្នចេញដោយអាជ្ញាធរមានសមត្ថកិច្ច
  - ក្រុមហ៊ុន៖ វិញ្ញាបនបត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងបណ្ណពន្ធប៉ាតង់ ច្បាប់ចម្លងដែលមានបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច
- វិញ្ញាបនបត្រត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានជំនិះ
- បំពេញកាតព្វកិច្ចពន្ធ និងអាករ (ករណីយានជំនិះមានបង្កាន់ដៃពន្ធយានយន្តជាបន្ទុករបស់រដ្ឋ)
- បង្កាន់ដៃពន្ធប្រថាប់ត្រាលើការផ្ទេរកម្មសិទ្ធិយានយន្ត (ជាទម្រង់ឌីជីថល) ក្នុងករណីយានជំនិះមានបង្កាន់ដៃពន្ធយានយន្តមិនមែនជាបន្ទុករបស់រដ្ឋ
- លិខិតលក់ទិញដែលមានចុះហត្ថលេខា និងបោះត្រារបស់ស្ថានទូត អង្គការ។

## ៥. ការផ្ទេរកម្មសិទ្ធិយានជំនិះក្រោមរបបគយនាំចូលបណ្ដោះអាសន្នទៅរូបវន្តបុគ្គល ឬនីតិបុគ្គលឯកជន

- ពាក្យសុំផ្ទេរកម្មសិទ្ធិយានជំនិះ
- បណ្ណសម្គាល់យានជំនិះ (ច្បាប់ដើម) និងផ្លាកលេខសម្គាល់យានជំនិះ
- អត្តសញ្ញាណអ្នកទិញ
  - ពលរដ្ឋខ្មែរ៖ អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ច្បាប់ចម្លងដែលមានបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច
  - ជនបរទេស៖ លិខិតឆ្លងដែន និងទិដ្ឋាការមានសុពលភាព និងលិខិតបញ្ជាក់ទីលំនៅបច្ចុប្បន្នចេញដោយអាជ្ញាធរមានសមត្ថកិច្ច
  - ក្រុមហ៊ុន៖ វិញ្ញាបនបត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងបណ្ណពន្ធប៉ាតង់ ច្បាប់ចម្លងដែលមានបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច
- បំពេញកាតព្វកិច្ចពន្ធ និងអាករ
- វិញ្ញាបនបត្រត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានជំនិះ
- លិខិតលក់ទិញដែលមានចុះហត្ថលេខាបោះត្រាក្រុមហ៊ុន ឬក្រសួង ស្ថាប័ន និងស្នាមមេដៃអ្នកទិញ។

ក្នុងករណីអាសយដ្ឋានបច្ចុប្បន្ន ខុសពីអាសយដ្ឋានដែលមាននៅក្នុងអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ត្រូវភ្ជាប់សៀវភៅគ្រួសារ ឬសៀវភៅស្នាក់នៅ ដែលមានបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច។

ក្នុងករណីម្ចាស់យានជំនិះដែលមានលិខិតរក្សាលេខចុះបញ្ជី និងវិញ្ញាបនបត្របញ្ជាក់ការទិញ ឬដេញថ្លៃលេខចុះបញ្ជីបាន ត្រូវភ្ជាប់លិខិតទាំងនោះមកជាមួយ។

ទម្រង់នៃពាក្យសុំផ្ទេរកម្មសិទ្ធិយានជំនិះ ទម្រង់នៃលិខិតលក់ទិញ ទម្រង់នៃវិក្កយបត្រអាករ គឺមានចែងនៅក្នុងឧបសម្ព័ន្ធទី១ ទី២ និងទី៣ នៃប្រកាសនេះ។

**ប្រការ៦.-**

ការផ្ទេរកម្មសិទ្ធិយានជំនិះគ្រប់ប្រភេទ ទៅជាកម្មសិទ្ធិគ្រប់គ្រងដោយក្រសួង ស្ថាប័ន ស្ថានទូត អង្គការសហប្រជាជាតិ អង្គការជាតិ អន្តរជាតិ ត្រូវភ្ជាប់ឯកសារដូចខាងក្រោម៖

- ពាក្យសុំផ្ទេរកម្មសិទ្ធិយានជំនិះ
- បណ្ណសម្គាល់យានជំនិះ (ច្បាប់ដើម) និងផ្លាកលេខសម្គាល់យានជំនិះ
- វិញ្ញាបនបត្រត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានជំនិះ
- អត្តសញ្ញាណអ្នកលក់៖
    - ពលរដ្ឋខ្មែរ៖ អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ច្បាប់ចម្លងដែលមានបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច
    - ជនបរទេស៖ លិខិតឆ្លងដែន និងទិដ្ឋាការមានសុពលភាព និងលិខិតបញ្ជាក់ទីលំនៅបច្ចុប្បន្នចេញដោយអាជ្ញាធរមានសមត្ថកិច្ច
    - ក្រុមហ៊ុន៖ វិញ្ញាបនបត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងបណ្ណពន្ធប៉ាតង់ ច្បាប់ចម្លងដែលមានបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច
- លិខិតលក់ទិញ ឬករណីយានជំនិះជាអំណោយ ត្រូវភ្ជាប់មកជាមួយនូវលិខិតប្រគល់ ទទួលដែលមានចុះហត្ថលេខា និងមានបោះត្រារបស់ក្រសួង ស្ថាប័ន ស្ថានទូត អង្គការ
- លិខិតស្នើសុំរបស់ក្រសួង ស្ថាប័ន ឬក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ សម្រាប់ស្ថានទូត អង្គការសហប្រជាជាតិ អង្គការអន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាលបរទេស ឬលិខិតបញ្ជាក់របស់ក្រសួងមហាផ្ទៃ សម្រាប់អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក។

**ប្រការ៧.-**

ដើម្បីគ្រប់គ្រងនិងការពារបាននូវភាពជាម្ចាស់កម្មសិទ្ធិលើយានជំនិះ ដែលបានចុះបញ្ជីរួច ត្រូវធ្វើការផ្ទេរកម្មសិទ្ធិឱ្យស្របតាមច្បាប់រវាងអ្នកលក់ អ្នកទិញ អ្នកកាន់កាប់យានជំនិះ។ អ្នកលក់ អ្នកទិញ អ្នកកាន់កាប់យានជំនិះត្រូវមានកាតព្វកិច្ចអនុវត្តដូចខាងក្រោម៖

- ត្រូវមកផ្តិតស្នាមមេដៃបំពេញបែបបទផ្ទេរកម្មសិទ្ធិយានជំនិះ នៅចំពោះមុខមន្ត្រីទទួលបន្ទុកផ្ទេរកម្មសិទ្ធិយានជំនិះ នៅតាមទីតាំងផ្តល់សេវាសាធារណៈរបស់ក្រសួងសាធារណការ និងដឹកជញ្ជូនដោយផ្ទាល់។
- ក្នុងករណីយានជំនិះពុំអាចរកម្ចាស់ដើមឃើញដែលត្រូវបានលក់ទិញបន្តគ្នា អ្នកកាន់កាប់យានជំនិះត្រូវទៅផ្តិតស្នាមដៃលើកិច្ចសន្យាជានានៅប៉ុស្តិ៍នគរបាលរដ្ឋបាល ដែលខ្លួនរស់នៅ រួចមកបំពេញបែបបទផ្ទេរកម្មសិទ្ធិយានជំនិះនៅចំពោះមុខមន្ត្រីទទួលបន្ទុកផ្ទេរកម្មសិទ្ធិយានជំនិះ នៅតាមទីតាំងផ្តល់សេវាសាធារណៈរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន។

ទម្រង់កិច្ចសន្យាជានា គឺមានចែងនៅក្នុងឧបសម្ព័ន្ធទី៤ នៃប្រកាសនេះ។

**ប្រការ៨.-**

ការផ្ទេរកម្មសិទ្ធិពីលេខចុះបញ្ជីរបស់ ក្រសួង ស្ថាប័ន ស្ថានទូត អង្គការសហប្រជាជាតិ អង្គការជាតិ អន្តរជាតិ និងយានជំនិះក្រោមរបបគយនាំចូលបណ្តោះអាសន្ន (AT) ទៅលេខចុះបញ្ជីពិសេសផ្ទាល់ខ្លួន មិនតម្រូវឱ្យបង់កម្រៃសេវារក្សាទុកលេខចុះបញ្ជីនោះទេ។

ការផ្ទេរកម្មសិទ្ធិយានជំនិះគ្រប់ប្រភេទ ត្រូវធ្វើបច្ចុប្បន្នភាពលេខចុះបញ្ជីរបស់រថយន្តចាស់ ទៅបំពាក់លើរថយន្តថ្មី ហើយរថយន្តចាស់ត្រូវចុះបញ្ជីយកលេខចុះបញ្ជីថ្មីឱ្យបានចប់សព្វគ្រប់ក្នុងពេលតែមួយ ករណីនេះមិនតម្រូវឱ្យបង់កម្រៃរក្សាទុកលេខចុះបញ្ជីទេ។

**ប្រការ៩.-**

ការផ្ទេរកម្មសិទ្ធិយានជំនិះគ្រប់ប្រភេទ តម្រូវឱ្យបង់៖

១.កម្រៃសេវាសាធារណៈ តាមការកំណត់ក្នុងប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន។

២.ពន្ធប្រថាប់ត្រាលើការផ្ទេរកម្មសិទ្ធិស្របតាមច្បាប់ និងបទប្បញ្ញត្តិស្តីពីពន្ធដារជាធរមាន។

៣.ប្រាក់កម្រៃសេវារបស់ក្រសួងសាធារណការ និងដឹកជញ្ជូន និងពន្ធប្រថាប់ត្រាផ្ទេរកម្មសិទ្ធិយានជំនិះរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនឹងត្រូវគណនាដោយស្វ័យប្រវត្តិតាមប្រព័ន្ធស្វ័យប្រវត្តិកម្មផ្ទេរកម្មសិទ្ធិយានជំនិះរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន។ ប្រជាពលរដ្ឋអាចធ្វើការបោះពុម្ពវិក្កយបត្ររួម និងបង់ប្រាក់តាមរយៈគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុជាដៃគូរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន និងអគ្គនាយកដ្ឋានពន្ធដារ។

៤.ការបង់កម្រៃសេវាសាធារណៈ និងការបង់ពន្ធប្រថាប់ត្រា ដូចមានចែងក្នុងកថាខណ្ឌ១ និងកថាខណ្ឌ២ នៃប្រកាសនេះ ត្រូវអនុវត្តតាមគំនូសបំព្រួញអំពីដំណើរការនៃការផ្ទេរកម្មសិទ្ធិយានជំនិះដូចមានចែងក្នុងឧបសម្ព័ន្ធទី១ នៃប្រកាសនេះ។

**ប្រការ១០.-**

អគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវគោក ត្រូវគ្រប់គ្រង តាមដាន ត្រួតពិនិត្យ និងណែនាំអនុវត្តនីតិវិធីនៃការផ្ទេរកម្មសិទ្ធិយានជំនិះស្របតាមប្រកាសអន្តរក្រសួងនេះឱ្យមានប្រសិទ្ធភាពខ្ពស់។

អគ្គនាយកដ្ឋានពន្ធដារ ត្រូវគ្រប់គ្រង តាមដាន ត្រួតពិនិត្យ និងណែនាំអនុវត្តនីតិវិធីនៃការបង់ពន្ធប្រថាប់ត្រាលើការផ្ទេរកម្មសិទ្ធិយានជំនិះស្របតាមប្រកាសអន្តរក្រសួងនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់។

**ប្រការ១១.-**

អគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវគោក នាយកដ្ឋានព័ត៌មានវិទ្យា និងទំនាក់ទំនងសាធារណៈ នៃក្រសួងសាធារណការ និងដឹកជញ្ជូន និងអគ្គនាយកដ្ឋានពន្ធដារ ត្រូវអនុវត្តដំណើរការនៃការចែករំលែកទិន្នន័យរវាងអង្គភាពទាំងពីរ ការរក្សាសុវត្ថិភាព និងការសម្ងាត់ អនុលោមតាមសេចក្តីសម្រេចរួមស្តីពីការតភ្ជាប់ប្រព័ន្ធស្វ័យប្រវត្តិកម្មដឹកជញ្ជូនផ្លូវគោក និងប្រព័ន្ធទិន្នន័យអគ្គនាយកដ្ឋានពន្ធដារ។

**ប្រការ១២.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយពីប្រកាសអន្តរក្រសួងនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ១៣.-**

អគ្គលេខាធិការ នាយកខុទ្ទកាល័យ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក អគ្គនាយកដឹកជញ្ជូនផ្លូវគោក អគ្គាធិការ ប្រធាននាយកដ្ឋាន និងអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសាធារណការ និងដឹកជញ្ជូន និងអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ៩កើត ខែភទ្របទ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ សីហា ឆ្នាំ២០២០

| | |
|---|---|
| **ឧបនាយករដ្ឋមន្ត្រី** | **ទេសរដ្ឋមន្ត្រី** |
| **រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** | **រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន** |
| អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន | ស៊ុន ចាន់ថុល |

**កន្លែងទទួល៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- រដ្ឋបាលរាជធានី ខេត្ត
- ដូចប្រការ១៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ឧបសម្ព័ន្ធទី១**

**នៃប្រកាសលេខ.................... ចុះថ្ងៃទី........... ខែ.............. ឆ្នាំ.................**

**ស្តីពីបែបបទ និងនីតិវិធីនៃការផ្ទេរកម្មសិទ្ធិយានជំនិះ**

**ទម្រង់ពាក្យស្នើសុំផ្ទេរកម្មសិទ្ធិយានជំនិះ**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសាធារណការ និងដឹកជញ្ជូន**
**អគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវគោក**

**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**
**អគ្គនាយកដ្ឋានពន្ធដារ**

# ពាក្យស្នើសុំផ្ទេរកម្មសិទ្ធិយានជំនិះ

## I. ព័ត៌មានយានជំនិះ

| | | | | | | | |
|---|---|---|---|---|---|---|---|
| ផ្លាកលេខចាស់ | | ឆ្នាំផលិត | | ចំនួនភ្លៅ | | ទម្ងន់យាន | |
| ផ្លាកលេខថ្មី | | ចង្កូត | | ចំនួនស៊ីឡាំង | | ទម្ងន់សរុប | |
| ម៉ាក | | ពណ៌ | | ទំហំស៊ីឡាំង | | ចំនួនកៅអី | |
| ប្រភេទ | | ប្រភេទប្រេង | | កម្លាំងសេះ | | លេខសាក់ស៊ី | |
| លេខតួ | | | | លេខម៉ាស៊ីន | | | |

បិទលេខឆ្លិតបម្លងជាក់ស្តែង (លេខតួ លេខសាក់ស៊ី)

បិទលេខឆ្លិតបម្លងជាក់ស្តែង (លេខម៉ាស៊ីន)

## II. ព័ត៌មានអ្នកលក់ និងអ្នកទិញ

### ១. ព័ត៌មានអ្នកលក់

| □ រូបវន្តបុគ្គល | □ នីតិបុគ្គល | |
|---|---|---|
| ឈ្មោះខ្មែរ | នាមករណ៍ខ្មែរ | |
| ឈ្មោះឡាតាំង | នាមករណ៍ឡាតាំង | |
| □ អត្ត.ប័ណ្ណ<br>□ លិខិតឆ្លងដែន | អត្ត.សារពើពន្ធ | |
| ថ្ងៃខែឆ្នាំកំណើត | ថ្ងៃខែចុះបញ្ជី | ថ្ងៃ / ខែ / ឆ្នាំ |

| | | | |
|---|---|---|---|
| ផ្ទះលេខ/អាគារ | | ផ្លូវ | |
| ភូមិ | | ឃុំ/សង្កាត់ | |
| ស្រុក/ខណ្ឌ | | ខេត្ត/រាជធានី | |
| សារអេឡិចត្រូនិច | | | |
| លេខទូរសព្ទ | | | |

### ២. ព័ត៌មានអ្នកទិញ

| □ រូបវន្តបុគ្គល | □ នីតិបុគ្គល | |
|---|---|---|
| ឈ្មោះខ្មែរ | នាមករណ៍ខ្មែរ | |
| ឈ្មោះឡាតាំង | នាមករណ៍ឡាតាំង | |
| □ អត្ត.ប័ណ្ណ<br>□ លិខិតឆ្លងដែន | អត្ត.សារពើពន្ធ | |
| ថ្ងៃខែឆ្នាំកំណើត | ថ្ងៃខែចុះបញ្ជី | ថ្ងៃ / ខែ / ឆ្នាំ |

| | | | |
|---|---|---|---|
| ផ្ទះលេខ/អាគារ | | ផ្លូវ | |
| ភូមិ | | ឃុំ/សង្កាត់ | |
| ស្រុក/ខណ្ឌ | | ខេត្ត/រាជធានី | |
| សារអេឡិចត្រូនិច | | | |
| លេខទូរសព្ទ | | | |

ប្រភេទផ្ទេរសិទ្ធិ □ទិញលក់ □អំណោយ □ផ្សេងៗ

➢ សូមបញ្ជាក់ថ្ងៃខែឆ្នាំលក់ (ករណីទិញ-លក់) ថ្ងៃ / ខែ / ឆ្នាំ

## III. តម្លៃត្រូវបង់ពន្ធប្រថាប់ត្រា

| មូលដ្ឋានគិតពន្ធ | X អត្រាពន្ធ (៤%) = | តំលៃពន្ធសរុប |
|---|---|---|
| | X ៤% = | |

ពិន័យលើភាពយឺតយ៉ាវក្នុងការបង់ពន្ធមធ្យោបាយ

| | | |
|---|---|---|
| | | |

## IV. ការធានាអះអាងរបស់អ្នកស្នើសុំ

ខ្ញុំបាទ/នាងខ្ញុំ សូមធានាថារាល់ឯកសារ និងព័ត៌មានដែលបានបំពេញក្នុងពាក្យស្នើសុំខាងលើ និងភ្ជាប់នៅក្នុងពាក្យស្នើសុំនេះពិតជាត្រឹមត្រូវ។

| | |
|---|---|
| កាលបរិច្ឆេទ | ថ្ងៃ / ខែ / ឆ្នាំ |
| ហត្ថលេខា<br>ឬស្នាមមេដៃ<br>ឬត្រាក្រុមហ៊ុន | |
| ឈ្មោះ | |

**ឧបសម្ព័ន្ធទី២**

**នៃប្រកាសលេខ...................... ចុះថ្ងៃទី............ ខែ.............. ឆ្នាំ..................**

**ស្តីពីបែបបទ និងនីតិវិធីនៃការផ្ទេរកម្មសិទ្ធិយានជំនិះ**

# ទម្រង់លិខិតលក់ទិញ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

## <u>លិខិតលក់ទិញ</u>

ខ្ញុំបាទ/នាងខ្ញុំ/ស្ថាប័នឈ្មោះ..................................ភេទ...........អាយុ............ឆ្នាំ ជនជាតិ..............
សញ្ជាតិ....................កាន់អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែនលេខ............................អាសយដ្ឋានបច្ចុប្បន្ន
ផ្ទះលេខ.............ផ្លូវ.............ភូមិ....................ឃុំ/សង្កាត់.......................ក្រុង/ស្រុក/ខណ្ឌ......................
រាជធានី/ខេត្ត.....................មុខរបរ.....................លេខទូរស័ព្ទ.......................អ៊ីម៉ែល........................។
បានលក់យានជំនិះ.................................០១គ្រឿង (មួយគ្រឿង) ដែលមានភិនភាគដូចខាងក្រោម៖

ផ្លាកលេខ...........................ម៉ាក.........................ប្រភេទ........................ពណ៌......................
ចំនួនស៊ីឡាំង...................ទំហំស៊ីឡាំង..................ចំនួនភ្លៅ...................លេខម៉ាស៊ីន.........................
លេខតួ..........................................លេខសាក់ស៊ី.......................... ទៅឱ្យឈ្មោះ/ស្ថាប័ន......................
ភេទ..............អាយុ............ឆ្នាំ...................ជនជាតិ...............សញ្ជាតិ.............កាន់អត្តសញ្ញាណប័ណ្ណ
ឬលិខិតឆ្លងដែនលេខ..........................អាសយដ្ឋានបច្ចុប្បន្នផ្ទះលេខ.............ផ្លូវ.............ភូមិ..................
ឃុំ/សង្កាត់..................ក្រុង/ស្រុក/ខណ្ឌ..................រាជធានី/ខេត្ត.....................មុខរបរ........................
លេខទូរស័ព្ទ...........................................អ៊ីម៉ែល.........................................................។

អ្នកកាន់កាប់យានជំនិះជាក់ស្តែង ដែលត្រូវបានលក់ទិញបន្តគ្នា និងមិនអាចរកម្ចាស់ដើមឃើញ ហើយមានបំណងធ្វើជាម្ចាស់កម្មសិទ្ធិយានជំនិះ ក្នុងករណីនេះតម្រូវយកស្នាមមេដៃកាន់កាប់ជាក់ស្តែងតែប៉ុណ្ណោះ។

សូមធានាទទួលខុសត្រូវថា យានជំនិះខាងលើពិតជាកម្មសិទ្ធិរបស់ខ្ញុំបាទ/នាងខ្ញុំ/ស្ថាប័ន ពិតប្រាកដមែន។ បើថ្ងៃក្រោយមានជនណាមកអះអាងផ្ទុយពីការធានាខាងលើ ខ្ញុំបាទ/នាងខ្ញុំ/ស្ថាប័ន សូមធានាទទួលខុសត្រូវចំពោះមុខច្បាប់ជាធរមាន។

ដើម្បីជាសក្ខីភាពនៃការធានារបស់ខ្ញុំបាទ/នាងខ្ញុំ/ស្ថាប័ន និងសាក្សី សូមផ្តិតមេដៃស្តាំ ឬបោះត្រាទុកជាភស្តុតាងតាមផ្លូវច្បាប់។

ថ្ងៃ.........................ខែ...................ឆ្នាំ...............ព.ស............

....................... ថ្ងៃទី.................ខែ..................ឆ្នាំ២០..........

**ស្នាមមេដៃអ្នកលក់ សាក្សីទី១ សាក្សីទី២ ស្នាមមេដៃអ្នកទិញ/អ្នកកាន់កាប់យានជំនិះ**

## ឧបសម្ព័ន្ធទី៣

## ប្រកាសលេខ.................... ចុះថ្ងៃទី........... ខែ............. ឆ្នាំ.................

## ស្តីពីបែបបទ និងនីតិវិធីនៃការផ្ទេរកម្មសិទ្ធិយានជំនិះ

## ទម្រង់វិក្កយបត្រអាករ

រូបសញ្ញារបស់ក្រុមហ៊ុន
LOGO

## ឈ្មោះក្រុមហ៊ុនជាភាសាខ្មែរ

COMPANY NAME

ឧបសម្ព័ន្ធទី២
Annex 2

លេខអត្តសញ្ញាណកម្ម អតប (VATTIN) ☐☐☐☐ – ☐☐☐☐☐☐☐☐☐

អាសយដ្ឋាន៖ ផ្ទះលេខ ផ្លូវ ឃុំ/សង្កាត់
Address No Street Commune/Sangkat

ក្រុង/ស្រុក/ខណ្ឌ រាជធានី/ខេត្ត លេខទូរស័ព្ទ
Town/District/Khan City /Province Telephone N°

---

## វិក្កយបត្រអាករ

**TAX INVOICE**

▶ អ្នកលក់យានយន្ត ◀

**អតិថិជន** / Customer:

ឈ្មោះក្រុមហ៊ុន ឬអតិថិជន ....................
Company name/ Customer

ទូរស័ព្ទលេខ ....................
Telephone N°

លេខរៀងវិក្កយបត្រ៖ ....................
invoice N°

កាលបរិច្ឆេទ ៖ ☐☐ ☐☐ ☐☐☐☐
Date

ម៉ោង ៖ ☐☐ ☐☐
Time

លេខអត្តសញ្ញាណកម្ម អតប (VATIN) ☐☐☐☐ - ☐☐☐☐☐☐☐☐☐ (ប្រសិនជាមាន / if any)

| ល.រ<br>N° | បរិយាយមុខទំនិញ<br>Description | បរិមាណ<br>Quantity | ថ្លៃឯកតា<br>Unit Price | ថ្លៃទំនិញ<br>Amount |
|---|---|---|---|---|
| 1 | រថយន្ត Rav4 ពណ៌ស ឆ្នាំផលិត 2012 លេខតួ៖............លេខម៉ាស៊ីន | 1 | $ 11,000.00 | $ 11,000.00 |
| 2 | | | | |
| 3 | | | | |
| 4 | | | | |
| 5 | | | | |
| 6 | | | | |
| 7 | | | | |
| 8 | | | | |

| | |
|---|---|
| រថយន្ត Rav4 សេរី 2012 លេខតួ៖.................... | $ 11,000.00 |
| សរុប/Total | $ |
| អាករលើតម្លៃបន្ថែម /VAT(10%) $ | $ 1,100.00 |
| **សរុបរួម /Grand Total** | $ 12,100.00 |

ហត្ថលេខា និងឈ្មោះអ្នកទិញ
Customer's Signature & Name

ហត្ថលេខា និងឈ្មោះអ្នកលក់
Seller's Signature & Name

សម្គាល់៖ ច្បាប់ដើមសម្រាប់អ្នកទិញ ច្បាប់ចម្លងសម្រាប់អ្នកលក់
Note: Original invoice for customer, copied invoice for seller

**ឧបសម្ព័ន្ធទី៤**

**ប្រកាសលេខ...................... ចុះថ្ងៃទី............ ខែ.............. ឆ្នាំ...............**

**ស្តីពីបែបបទ និងនីតិវិធីនៃការផ្ទេរកម្មសិទ្ធិយានជំនិះ**

# ទម្រង់កិច្ចសន្យាធានា

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

| រូបថត<br>៤x៦ |
|---|

## កិច្ចសន្យាធានា

ខ្ញុំបាទ/នាងខ្ញុំ.......................................ភេទ..................អាយុ.................ជនជាតិ.................. សញ្ជាតិ............................កាន់អត្តសញ្ញាណប័ណ្ណលេខ..............................................អាសយដ្ឋានបច្ចុប្បន្នផ្ទះលេខ..................ផ្លូវលេខ..................ភូមិ........................ឃុំ/សង្កាត់.............................. ក្រុង/ស្រុក/ខណ្ឌ..............................រាជធានី/ខេត្ត..............................មុខរបរ................................ លេខទូរស័ព្ទ.......................................... អ៊ីម៉ែល...............................................................។

ខ្ញុំបាទ/នាងខ្ញុំ សូមធានាទទួលខុសត្រូវចំពោះយានជំនិះ ដែលមានភិនភាគដូចខាងក្រោម៖

ផ្លាកលេខ.........................ម៉ាក.......................................ប្រភេទ.......................................... ពណ៌....................ចំនួនស៊ីឡាំង.......................ទំហំស៊ីឡាំង..................ចំនួនភ្លៅ........................... លេខម៉ាស៊ីន.................................លេខតួ...............................លេខសាក់ស៊ី.................................. ពិតជាកម្មសិទ្ធិរបស់ខ្ញុំបាទ/នាងខ្ញុំពិតប្រាកដមែន។

សូមធានាទទួលខុសត្រូវថា យានជំនិះខាងលើពិតជាកម្មសិទ្ធិរបស់ខ្ញុំបាទ/នាងខ្ញុំ ពិតប្រាកដមែន។ បើថ្ងៃក្រោយមានជនណាមកអះអាងផ្ទុយពីការធានាខាងលើ ខ្ញុំបាទ/នាងខ្ញុំ សូមធានាទទួលខុសត្រូវចំពោះមុខច្បាប់ជាធរមាន។

ដើម្បីជាសក្ខីភាពនៃការធានារបស់ខ្ញុំបាទ/នាងខ្ញុំ សូមផ្តិតមេដៃស្តាំ ទុកជាភស្តុតាងតាមផ្លូវច្បាប់។

ថ្ងៃ.......................ខែ.............ឆ្នាំ................ព.ស.........

............................ ថ្ងៃទី...........ខែ..........ឆ្នាំ២០.........

**ស្នាមមេដៃអ្នកកាន់កាប់យានជំនិះ**

លេខ...............................

បានឃើញ និងបញ្ជាក់ថា៖

ម្ចាស់យានជំនិះឈ្មោះ...................................................

ដែលមានទីលំនៅក្នុងឃុំ/សង្កាត់........................................

ពិតជាបានមកផ្តិតមេដៃធានាអះអាងជាម្ចាស់យាន មានផ្លាកលេខ

....................................នៅចំពោះមុខយើងពិតប្រាកដមែន។

ថ្ងៃ....................ខែ...................ឆ្នាំ.............ព.ស......

...................... ថ្ងៃទី....................ខែ..............ឆ្នាំ ២០....

**នាយប៉ុស្តិ៍នគរបាលរដ្ឋបាល.......................................**

## ឧបសម្ព័ន្ធទី.០៥

## នៃប្រកាសលេខ...................... ចុះថ្ងៃទី............ខែ..............ឆ្នាំ..................

## ស្តីពីបែបបទនិងនីតិវិធីនៃការផ្ទេរកម្មសិទ្ធិយានជំនិះ

## គំនូសបំព្រួញអំពីដំណើរការនៃការផ្ទេរកម្មសិទ្ធិយានជំនិះ




*សម្គាល់៖ ប្រអប់ "**បន្ទាត់ជាប់**" សម្គាល់ដំណើរការដោយ មន្ត្រី / អ្នកដាក់ពាក្យ / អ្នកលក់ / អ្នកទិញ

ប្រអប់ "**បន្ទាត់ដាច់ៗ**" សម្គាល់ដំណើរការដោយ ប្រព័ន្ធដោយស្វ័យប្រវត្តិ